**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :...០១...សរណន**

# សារាចរណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា

ដោយសង្កេតឃើញថា អ្នកដឹកនាំតៃវ៉ាន់មួយចំនួន បានមកប្រទេសកម្ពុជា ដើម្បីជួបសំណេះសំណាលជាមួយតំណាងស្ថាប័នខ្លះៗ ក្នុងរូបភាពឯកជន និង តាមពត៌មានបានអោយដឹងថា មានគំរោងការអោយវិស័យឯកជនអញ្ជើញអ្នកដឹកនាំកម្ពុជា ទៅទស្សនកិច្ចនៅតៃវ៉ាន់ តាមរូបភាពផ្សេងៗ ដូចជា ទៅសំរាកលំហែកាយជាដើម រាជរដ្ឋាភិបាលកម្ពុជាសូមបញ្ជាក់ជាថ្មីម្តងទៀត នូវជំហរឥតងាករេរបស់ខ្លួនក្នុងការគាំទ្រ "គោលនយោបាយចិនមួយ " ហើយបដិសេធទាំងស្រុង នូវរាល់សកម្មភាពដែលមានបំណងបំបែកបំបាក់ប្រទេសចិនជាពីរ ដោយផ្តាច់តៃវ៉ាន់ពីមហាប្រទេសចិន ។

រាជរដ្ឋាភិបាលកម្ពុជា សូមធ្វើការណែនាំដល់មន្ត្រីរាជការ និងសមាជិក-សមាជិកានៃរាជរដ្ឋាភិបាលកម្ពុជា អោយជៀសវាងធ្វើទំនាក់ទំនងតាមរូបភាពជាផ្លូវការ ជាមួយថ្នាក់ដឹកនាំតៃវ៉ាន់ ដែលជាការជើរជ្ជុយនឹងជំហររបស់រាជរដ្ឋាភិបាលកម្ពុជា ។

ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលកម្ពុជា បដិសេធផ្តល់ទិដ្ឋាការផ្លូវការនិងទិដ្ឋាការការទូត ដល់ជនជាតិចិនតៃវ៉ាន់នៅគ្រប់ច្រកចេញ-ចូលអន្តរជាតិ នៅក្នុងប្រទេសកម្ពុជា ។

រាជរដ្ឋាភិបាលនិងប្រជាពលរដ្ឋកម្ពុជា ជានិច្ចកាលបន្តពង្រឹងពង្រីកទំនាក់ទំនងមិត្តភាពជាប្រពៃណី និងកិច្ចសហប្រតិបត្តិការល្អ ជាមួយរដ្ឋាភិបាលនិងប្រជាពលរដ្ឋចិន អោយកាន់តែរឹងមាំថែមទៀត ដើម្បីជាផលប្រយោជន៍រួមនៃប្រទេសទាំងពីរ ។

ក្រោយពីទទួលបានការណែនាំនេះ មន្ត្រីរាជការ និងសមាជិក-សមាជិកានៃរាជរដ្ឋាភិបាល ត្រូវអនុវត្តតាមសារាចរណែនាំនេះ អោយមានប្រសិទ្ធភាពខ្ពស់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ មករា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**